# ព័ត៌មានស្តីពី ការចាក់វ៉ាក់សាំងកូវីដ-១៩ ដល់ជនបរទេស ស្នាក់នៅក្នុងប្រទេសកូរ៉េ

ការកក់ទុកជាមុនត្រូវបានធ្វើឡើងទៅតាមស្តង់ដារនិង នីតិវិធីដូចគ្នាដោយមិនមានការបែងចែកជនជាតិកូរ៉េ ឬជនបរទេសឡើយ។ សូមធ្វើការកក់ចាក់វ៉ាក់សាំងកូវីដ១៩ ដោយពិនិត្យមើល អ្នកអាចទទួលចាក់វ៉ាក់សាំង និង វិធីសាស្រ្តការកក់ដូចខាងក្រោម។

## □ អ្នកទទួលការចាក់វ៉ាក់សាំង និងវិធីសាស្រ្តការកក់

- **ជនបរទេសដែលបានចុះឈ្មោះជាជនបរទេស**

  - អ្នកអាចដាក់ពាក្យសុំចាក់វ៉ាក់សាំង តាមលំដាប់លំដោយការចាក់ថ្នាំទៅតាម 'ផែនការការចាក់វ៉ាក់សាំងតាមគោលដៅនីមួយៗ នៅខែ សីហា-ខែកញ្ញា' អ្នកអាចកក់តាមប្រព័ន្ធអនឡាញ និងទូរស័ព្ទ។

    * ករណីពេលកក់តាមប្រព័ន្ធអនឡាញ បង្ហាញថាអ្នកមិនមានសិទ្ធិ អ្នកត្រូវទៅមណ្ឌលសុខភាពសាធារណៈក្នុងតំបន់ផ្ទាល់ អ្នកអាចធ្វើការកក់បាន បន្ទាប់ពីចុះឈ្មោះទទួលការចាក់ថ្នាំ

**- វិធីសាស្រ្តនៃការកក់ -**

◦ (ប្រព័ន្ធអនឡាញ - អាចបាន សាមីខ្លួននិងអ្នកតំណាង) ដាក់ពាក្យកក់តាមប្រព័ន្ធការកក់ទុកជាមុន ក្នុងការចាក់វ៉ាក់សាំង កូវីដ១៩ (http://ncvr2.kdca.go.kr) (អ្នកតំណាង អាចកក់ជំនួសអោយបាន)

◦ (ទូរស័ព្ទ - អាចបាន សាមីខ្លួននិងអ្នកតំណាង) ពិនិត្យមើលលេខ ការប្រឹក្សាយោបល់អំពីការកក់ ដោយរដ្ឋាភិបាលមូលដ្ឋាន នីមួយៗ នៅមជ្ឈមណ្ឌលត្រួតពិនិត្យនិងការពារជំងឺ(១៣៣៩)ឬតាមប្រព័ន្ធការកក់ទុកជាមុនក្នុងការចាក់វ៉ាក់សាំងកូវីដ១៩(ស្ថានភាពបច្ចុប្បន្ន នៃការចាក់វ៉ាក់សាំង(បង្ហាញmouse)→ ចុចលើ ស្ថានភាពប្រតិបត្តិការការកក់តាមទូរស័ព្ទក្នុងការចាក់វ៉ាក់ សាំង កូវីដ១៩)

- **ជនបរទេសដែលមិនបានចុះលេខកាត ជាជនបរទេសស្នាក់នៅប្រទេសកូរ៉េ (រួមទាំងជនបរទេសដែលស្នាក់នៅខុសច្បាប់)**

  - ទៅមណ្ឌលសុខភាពសាធារណៈ ដើម្បីទទួលយកលេខគ្រប់គ្រងបណ្តោះអាសន្ន ជាមួយលិខិតឆ្លងដែនរបស់អ្នក និង ទទួលការកក់។

  * ទោះបីជាជនបរទេស មានលិខិតឆ្លងដែនដែលផុតសុពលភាពក៏ដោយ ត្រូវបង្ហាញលិខិតឆ្លងដែនដែលផុតសុពលភាព, កាតចុះឈ្មោះជនបរទេស ដែលផុតកំណត់នៃការស្នាក់នៅ និង ឯកសារបញ្ជាក់អត្តសញ្ញាណដែល ចេញដោយស្ថានទូតប្រចាំនៅប្រទេសកូរ៉េ។

  - អាចចេញជូន លេខគ្រប់គ្រងបណ្តោះអាសន្នបាន ប្រសិនបើម្ចាស់អាជីវកម្ម(ថៅកែ)បង្ហាញព័ត៌មានផ្ទាល់ខ្លួន(ឈ្មោះ, ថ្ងៃខែឆ្នាំកំណើត, ភេទ, សញ្ជាតិ, អាសយដ្ឋានទីលំនៅ·ទីកន្លែងធ្វើការ។ល។ )របស់ជនបរទេសដែលកំពុងធ្វើការ។

  - បន្ទាប់ពីចេញលេខគ្រប់គ្រងបណ្តោះអាសន្នរួច អ្នកអាចដាក់ពាក្យសុំកក់ការចាក់វ៉ាក់សាំង តាមប្រព័ន្ធអនឡាញ ឬ ទូរស័ព្ទបាន) (អាចកក់ជំនួសអោយបាន)

※ មិនអាចទទួលការចាក់វ៉ាក់សាំងបាន ចំពោះអ្នកដែលស្នាក់នៅរយៈពេលខ្លី ក្រោម៩០ថ្ងៃ ដោយគោលបំណងមកទស្សនកិច្ចទេសចរណ៍ប្រទេសកូរ៉េផ្សេងៗ

## □ ប្រការប្រុងប្រយ័ត្ន

- **ព័ត៌មានពីអត្តសញ្ញាណ គឺប្រើសម្រាប់គោលបំណងចាក់វ៉ាក់សាំងតែប៉ុណ្ណោះ, យោងតាមប្រព័ន្ធការលើកលែងកាតព្វកិច្ចជូនដំណឹង ការពិតការស្នាក់នៅមិនស្របច្បាប់ផ្សេងៗ មិនត្រូវបានជូនដំណឹង ដល់ស្នាក់ការអន្តោប្រវេសន៍· ការិយាល័យជនបរទេសឡើយ**

- ជនដែលមិនមានធានារ៉ាប់រងសុខភាព គឺអាចទទួលការចាក់វ៉ាក់សាំងបានតែនៅមណ្ឌលសុខភាពសាធារណៈ ឬ នៅមណ្ឌលចាក់វ៉ាក់សាំងប៉ុណ្ណោះ

  * មិនអាចទទួលការចាក់វ៉ាក់សាំង នៅតាមស្ថាប័នវេជ្ជសាស្រ្ត មន្ទីរពេទ្យ·គ្លីនិក ជាដើម

<បកប្រែដោយមជ្ឈមណ្ឌលប្រឹក្សាតាមទូរស័ព្ទដានូរី ១៥៧៧- ១៣៦៦>